# សំណួរ ពាក់ព័ន្ធនឹងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ (២)

# តើច្បាប់រដ្ឋធម្មនុញ្ញ មានចែងអំពីការកម្រិតសិទ្ធិដែរឬទេ (Restriction of Rights)?

**<u>ចម្លើយ</u>**

កតិកាសញ្ញា (Covenant) ស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ បានចែងកម្រិតសិទ្ធិពីរប្រភេទ ទី១ ការកម្រិតសិទ្ធិ ភ្ជាប់ជាមួយនឹងសិទ្ធិជាក់លាក់មួយចំនួន (inherent limitation of right) ដូចជាមាត្រា ១៩ (សេរីភាពសំដែងមតិ) និងកម្រិតនៅក្នុងពេលមានគ្រោះអាសន្នជាសាធារណៈ (មាត្រា ៤) (សូមមើលបន្ថែមសំណួរចម្លើយពាក់ព័ន្ធនឹងការកម្រិតសិទ្ធិនេះ)។[1]

មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ បានចែងអំពីការកម្រិតសិទ្ធិជាទូទៅ៖ *ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់* ។ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ ស្តីពី សេរីភាពបញ្ចេញមតិ ចែងនូវការកម្រិតភ្ជាប់ជាមួយ ហាមមិនឲ្យប្រើសេរីភាពនេះ ប៉ះពាល់ដល់ទំនៀមទម្លាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងសន្តិសុខជាតិ។ ជាចុងក្រោយ ការអនុវត្តជំនឿណាមួយ មិនត្រូវប៉ះពាល់ដល់ជំនឿដទៃ និង សន្តិសុខ ក៏ដូចជាសណ្តាប់ធ្នាប់សាធារណៈ។ ...*ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ <u>ដល់ទំនៀមទម្លាប់ល្អរបស់សង្គម</u> ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ*។

មានមាត្រាមួយចំនួន និយាយយោងដល់ស្ថានភាពគ្រោះអាសន្នសាធារណៈ ដែលអាចតម្រូវឲ្យមានការប្រកាសដាក់ប្រទេសក្នុងភាពអាសន្នដោយព្រះមហាក្សត្រ (មាត្រា ២២ ថ្មី) មាត្រា ៨៦, ១០២ ថ្មី, មាត្រា ១៥២ថ្មី ក៏ប៉ុន្តែ មិនបានចែងអំពីការកម្រិត ឬមិនកម្រិតសិទ្ធិមួយចំនួន ស្រដៀងនឹងមាត្រា ៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋនិងនយោបាយទេ។

**<u>កំណត់សំគាល់</u>**៖ មូលដ្ឋាននៃការកម្រិតសិទ្ធិ ក្នុងមាត្រាពាក់ព័ន្ធក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ខុសគ្នានឹងមូលដ្ឋានចែងក្នុងមាត្រានៃកតិកាសញ្ញា។ ដាក់ស្តែងមាត្រារបស់កតិកាសញ្ញា ១៩... *៣. ការប្រើប្រាស់សិទ្ធិដែលចែងក្នុងកថាខណ្ឌ២នៃមាត្រានេះតម្រូវឱ្យមានករណីយកិច្ចនិងការទទួលខុសត្រូវពិសេស។ដូច្នេះការប្រើប្រាស់សិទ្ធិនេះអាចមានការរឹតត្បិតមួយចំនួន ដែលត្រូវកំណត់ជាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី* ៖

---

[1] ពាក្យគន្លឹះសម្រាប់ Search គឺ absolute rights or limitation of rights.

*ក. គោរពសិទ្ធិ និងកិត្តិសព្ទរបស់អ្នកដទៃ ។*

*ខ. ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬ<u>សីលធម៌សាធារណៈ</u> ។*